**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសុខាភិបាល**

# សេចក្តីជូនព័ត៌មានរបស់ក្រសួងសុខាភិបាល
## ស្តីពី
## ការរកឃើញ ០៤ ករណីថ្មីទៀត ជាបុរសជនជាតិខ្មែរដែលវិលត្រឡប់មកពីចូលរួមពិធីសាសនានៅប្រទេសម៉ាឡេស៊ី និង ០៦ ករណីថ្មី ជាបុរសជនជាតិម៉ាឡេស៊ី វិជ្ជមានវីរុសកូវីដ១៩

ថ្ងៃទី១៩ ខែមីនា ឆ្នាំ២០២០ ក្រសួងសុខាភិបាល សូមគោរពជម្រាបជូនសាធារណជនទាំងអស់ ឲ្យបានជ្រាបថា លទ្ធផលពីវិទ្យាស្ថានប៉ាស្ទ័រកម្ពុជាបានបង្ហាញ **<u>វិជ្ជមានវីរុសកូវីដ១៩ ចំនួន១០នាក់</u>** ជាករណីថ្មីបន្ថែមទៀត ដែលមានដូចខាងក្រោមនេះ៖

**១. នៅខេត្តបាត់ដំបង៖** ០២ ករណី ជាជនជាតិខ្មែរ

- ស្ត្រីអាយុ ៣៥ឆ្នាំ ជាភរិយាបុរសអាយុ ៤៥ឆ្នាំ (វិជ្ជមានវីរុសកូវីដ១៩ ដែលបានជូនព័ត៌មានពីថ្ងៃម្សិលមិញនេះរួចហើយ) និងស្ត្រីអាយុ ៤១ឆ្នាំ ជាភរិយាបុរសអាយុ ៤២ឆ្នាំ (វិជ្ជមានវីរុសកូវីដ១៩ ដែលបានជូនព័ត៌មានពីថ្ងៃម្សិលមិញនេះរួចហើយ) រស់នៅភូមិសូភី២ សង្កាត់រតនៈ ក្រុងបាត់ដំបង មានលទ្ធផលតេស្តវិជ្ជមានកូវីដ១៩។ នេះ ជាករណីដំបូងដែលបានរកឃើញថាមានការឆ្លងពីស្វាមី ដែលបានវិលត្រឡប់មកពីចូលរួមពិធីសាសនានៅប្រទេសម៉ាឡេស៊ី។ ស្ត្រីទាំងពីរនាក់នេះ កំពុងដាក់នៅដាច់ដោយឡែកព្យាបាលនៅមន្ទីរពេទ្យខេត្តបាត់ដំបង។

សម្គាល់៖ ស្ត្រីអាយុ ៣៥ឆ្នាំ មានកូនស្រី០៤នាក់ (មានលទ្ធផលអវិជ្ជមានវីរុសកូវីដ១៩) និងស្ត្រីអាយុ ៤១ឆ្នាំ មានកូន ០៣នាក់ (ស្រី ០២ ប្រុស ០១ និងម្តាយក្មេក) ដែលក្រុមគ្រូពេទ្យបានយកសំណាកវត្ថុវិភាគរួចរាល់ហើយដែរ។

**២. នៅខេត្តកណ្តាល៖** ០១ ករណី ជាជនជាតិខ្មែរ

- បុរសអាយុ ៦០ឆ្នាំ នៅភូមិប៉ាវីនក្រោម ឃុំស្វាយប្រទាល ស្រុកស្អាង មានតេស្តវិជ្ជមានវីរុសកូវីដ១៩ ដែលត្រូវបានដាក់ឲ្យនៅព្យាបាលក្នុងមន្ទីរពេទ្យខេត្តកណ្តាល។

សម្គាល់៖ បុរសនេះ ជាអ្នកក្នុងចំណោម ៧៩នាក់ ដែលបានវិលត្រឡប់មកពីការចូលរួមពិធីសាសនានៅប្រទេសម៉ាឡេស៊ី។

**៣. នៅរាជធានីភ្នំពេញ៖** ០១ ករណី ជាជនជាតិខ្មែរ

- បុរសអាយុ ៣៤ឆ្នាំ មកធ្វើការងារសាសនាស្នាក់នៅព្រះវិហារឥស្លាម២-៣ថ្ងៃហើយក្នុងឃុំព្រែកប្រា សង្កាត់ច្បារ

អំពៅ១ (ផ្ទះគាត់មានអាស័យដ្ឋាននៅភូមិពោធិសាត់ ឃុំព្រៃថ្នង ខេត្តកំពត) នឹងយកមកដាក់នៅមន្ទីរពេទ្យចាក់អង្រែក្រោម រាជធានីភ្នំពេញ។

សម្គាល់៖ បុរសនេះជាអ្នកក្នុងចំណោម ៧៩នាក់ ដែលបានវិលត្រឡប់មកពីការចូលរួមពិធីសាសនានៅប្រទេសម៉ាឡេស៊ី។

**៤. នៅខេត្តកំពង់ចាម៖** ០៦ ករណី ជាជនជាតិម៉ាឡេស៊ី

- បុរសអាយុ ២៦ឆ្នាំ ៣៤ឆ្នាំ ៣៨ឆ្នាំ ៥១ឆ្នាំ ៥៨ឆ្នាំ និង៦២ឆ្នាំ ស្នាក់នៅបណ្តោះអាសន្នក្នុងស្រុកកងមាស

សម្គាល់៖ បុរសជនជាតិម៉ាឡេស៊ីទាំង០៦នាក់នេះ មកពីប្រទេសម៉ាឡេស៊ី ធ្វើការងារសាសនានៅតាមភូមិ ឃុំ នៅស្រុកកងមាស ខេត្តកំពង់ចាម។

**៥. សរុបករណីវិជ្ជមានវីរុសកូវីដ១៩ នៅទូទាំងប្រទេស៖**

ត្រឹមម៉ោង២១:០០ ថ្ងៃទី១៩ ខែមីនា ឆ្នាំ២០២០ ករណីវិជ្ជមានវីរុសកូវីដ១៩ សរុបទាំងអស់មានចំនួន ៤៧នាក់ (ស្រី ០៤នាក់ ប្រុស ៤៣នាក់) ដែលក្នុងនោះ មានជនជាតិ ចិន ១នាក់ (នៅខេត្តព្រះសីហនុ បានជាសះស្បើយ) អង់គ្លេស ៣នាក់ កាណាដា ១នាក់ បែលហ្ស៊ិក ១នាក់ បារាំង ២នាក់ (ក្នុងនេះមានកូនប្រុសបង្កើតអាយុ០៤ខែ) ម៉ាឡេស៊ី ១១នាក់ ខ្មែរ ២៨នាក់ (ក្នុងនេះ អ្នកដែលវិលត្រឡប់មកពីពិធីសាសនានៅប្រទេសម៉ាឡេស៊ី ២៣នាក់ និងមានស្ត្រី០២នាក់ (មិនបានធ្វើដំណើរទៅប្រទេសម៉ាឡេស៊ី) ជាភរិយាឆ្លងពីស្វាមី)។

ក្រុមការងាររបស់ក្រសួងសុខាភិបាល កំពុងតែធ្វើកិច្ចការស្រាវជ្រាវករណីថ្មីជាបន្តទៀត ហើយនឹងបន្តជម្រាបជូនដល់បងប្អូនសាធារណជន ប្រសិនបើមានរកឃើញករណីវិជ្ជមានវីរុសកូវីដ១៩ ថ្មីណាផ្សេងទៀត។

ក្រសួងសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជាទីបំផុត ជូនដល់ថ្នាក់ដឹកនាំ មន្ត្រី-បុគ្គលិកសុខាភិបាល និងក្រុមគ្រូពេទ្យទាំងអស់នៅទូទាំងប្រទេស ស្ថាប័ន និងអាជ្ញាធរពាក់ព័ន្ធទាំងអស់ ទាំងថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ អង្គការសុខភាពពិភពលោក មជ្ឈមណ្ឌលប្រយុទ្ធនឹងជំងឺឆ្លងសហរដ្ឋអាមេរិក និងវិទ្យាស្ថានប៉ាស្ទ័រកម្ពុជា ដែលបានខិតខំបំពេញភារកិច្ចបានល្អប្រសើរបំផុត ក្នុងការជួយពិនិត្យសុខភាព និងស្រាវជ្រាវរកករណីកូវីដ១៩ ព្រមទាំងអ្នកប៉ះពាល់ទាំងអស់កន្លងមក រួមទាំងការដាក់វិធានការនានា ដើម្បីទប់ស្កាត់ការចម្លងវីរុសកូវីដ១៩ នៅក្នុងប្រទេសកម្ពុជា។

ក្រសួងសុខាភិបាល បន្តជូនដំណឹងដល់សាធារណជនអំពីការវិវឌ្ឍនៃបញ្ហាសុខភាព តាមទំព័រហ្វេស ប៊ុក និងគេហទំព័ររបស់ក្រសួង www.cdcmoh.gov.kh ដែលគេហទំព័រនេះមានសម្ភារៈអប់រំសុខភាពដែលអាចទាញយកមកប្រើប្រាស់បាន។ សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងមកទូរស័ព្ទទាន់ហេតុការណ៍ ក្រសួងសុខាភិបាល លេខ ១១៥ ដោយឥតគិតថ្លៃ ឬទំនាក់ទំនងក្រសួងសុខាភិបាល តាមលេខទូរស័ព្ទ៖ ០១២ ៨២៥ ៤២៤ ឬ ០១២ ៤៨៨ ៩៨១ ឬ ០១២ ៨៣៦ ៨៦៨ ។

ថ្ងៃព្រហស្បតិ៍ ១១រោច ខែផល្គុន ឆ្នាំកុរ ឯកស័ក ព.ស. ២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី១៩ ខែមីនា ឆ្នាំ២០២០